ក្រុមសៀវភៅការរុករកឃើញ®



# សេចក្តីសុខ ដែលបានបាត់បង់

## ការស្វែងយល់ឡើងវិញ អំពីការរៀបចំរបស់ព្រះជាម្ចាស់ សម្រាប់បញ្ហាផ្លូវភេទរបស់មនុស្ស



**និពន្ធដោយ** : Gary Inrig



*សេចក្ដីផ្ដើម*

# សេចក្ដីសុខដែលបានបាត់បង់

## ការស្វែងយល់ឡើងវិញ អំពីការរៀបចំរបស់ព្រះជាម្ចាស់ សម្រាប់បញ្ហាផ្លូវភេទ

បញ្ហាផ្លូវភេទរបស់មនុស្ស គឺពិតជាមានអំណាចណាស់។ ក្រុមហ៊ុនជាច្រើនបានប្រើប្រាស់វា ដើម្បីទាក់ទាញមនុស្សឲ្យទិញផលិតផលគ្រប់ប្រភេទ រាប់ចាប់តាំងពីសម្លៀកបំពាក់ និងគ្រឿងសម្អាង រហូតដល់រថយន្ត និងការធ្វើដំណើរវិស្សមកាល។ រូបភាពស៊ិចស៊ី ឬទាក់ទងនឹងផ្លូវភេទបានលេចឡើង នៅក្នុងទំព័រទស្សនាវដ្ដី នៅលើកញ្ចក់ទូរទស្សន៍ ខ្សែភាពយន្ត ឬក្នុងតន្ត្រី នៅលើផ្លាកផ្សាយពាណិជ្ជកម្មនៅតាមផ្លូវ ហើយបានលេចឡើងច្រើនជាងគេ នៅតាមបណ្ដាញអ៊ីនធើណិត។

និយាយឲ្យខ្លី យើងកំពុងតែរស់នៅ ក្នុងសង្គមដែលជ្រួតជ្រាបទៅដោយបញ្ហាផ្លូវភេទ និងការចម្អែតផ្លូវអារម្មណ៍ខ្លួនឯង។ នៅក្នុងទំព័រជាបន្តបន្ទាប់នេះ យើងនឹងស្វែងយល់អំពីផ្លូវភេទ ដែលជាអំណោយដ៏ល្អដែលព្រះបានប្រទាន នៅក្នុងបរិបទនៃរឿងដ៏មានន័យ ក្នុងព្រះគម្ពីរ។ យើងនឹងអាចយល់អំពីគោលបំណងដែលព្រះទ្រង់មាន តាំងពីដំបូង សម្រាប់បញ្ហាផ្លូវភេទ និងបញ្ហាប្រឈមដែលមនុស្សបានបន្តជួបប្រទះ ដោយសារអំពើ

បាបបានធ្វើឲ្យមនុស្សមានការយល់ច្រឡំ អំពីការរៀបចំរបស់ព្រះ តាំងពីដើមដំបូងសម្រាប់បញ្ហាផ្លូវភេទ។

សូមចាំថា : សីលធម៌ផ្លូវភេទ គឺមិនគ្រាន់តែជាការជៀសវាងអំពើបាប ឬអ្វីដែលខុសនឹងព្រះហឫទ័យព្រះប៉ុណ្ណោះទេ តែក៏ជាការគោរព ចំពោះអ្វីមានតម្លៃ ដើម្បីជាប្រយោជន៍យើងរាល់គ្នា និងសម្រាប់ថ្វាយសិរីល្អដល់ព្រះ។

*Gary Inrig*

# មាតិកា


*ទី១* ទំព័រ

សេចក្តីសុខដែលបានបាត់បង់ ៥

*ទី២*

ចូរស្វែងយល់អំពីដើមកំណើតរបស់មនុស្ស ៩

*ទី៣*

អំពើបាបបានធ្វើឲ្យមនុស្សយកការសប្បាយផ្ទាល់ខ្លួនជាអទិភាព ១៤

*ទី៤*

ផ្លូវភេទ គឺជាជនរងគ្រោះទីមួយ នៃអំពើបាប ២០

*ទី៥*

គ្មានផ្លូវត្រឡប់បែរក្រោយ … មានតែផ្លូវទៅមុខ ២៧



MANAGING EDITOR: J. R. Hudberg

COVER IMAGE: Ira Heuvelman-Dobrolyubova via Getty Images

COVER DESIGN: Stan Myers

INTERIOR DESIGN: Steve Gier



Excerpted from Pure Desire by Gary Inrig, © 2010 by Gary Inrig. Used by permission of Discovery House. All rights reserved.



Interior Images: ( p.1 ) Ira Heuvelman-Dobrolyubova via Getty Images; ( p.5 ) Stella Bogdanic via RGBStock.com; ( p.9 ) PixelAnarchy via Pixabay.com; ( p.15 ) LoggaWiggler via Pixabay.com; ( p.21 ) Dorota Kaszczyszyn via FreeImages.com and Pezibear via Pixabay.com; ( p.27 ) Bjorn de Leeuw via FreeImages.com.

ប្រែសម្រួលជាភាសាខ្មែរដោយ លោកលី ប៊ុនថា

កែសម្រួលអត្ថបទដោយ លោកឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល។



រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2019 ODB Ministries ( website: www.odb.org )



ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@rbc.org, Tell: 087 233 907, website: http://khmer-odb.org, FB page : https://www.facebook.com/RBCCambodia )



*ទីមួយ*

# សេចក្តីសុខដែលបានបាត់បង់

**ការដើរកាត់តាមច្រកភ្នំស៊ីគ** ដ៏តូចចង្អៀត ឆ្ពោះទៅរកទីក្រុងពេត្រា ដែលជាទីក្រុងបុរាណ ក្នុងប្រទេសយ័រដាន់ គឺជាបទពិសោធន៍ដ៏មានន័យ។ ច្រកភ្នំនេះមានប្រវែងជិត១,៦ គីឡូម៉ែត្រ និងមានទទឹងមិនដល់៦ម៉ែត្រទេ តែវាបានតភ្ជាប់ផ្សារតូចៗមួយចំនួន ដែលកាលពីមុន គេបានដាក់តាំងគ្រឿងសក្ការៈរបស់សាសនា នៅទីនោះ ហើយថែមទាំងបានតភ្ជាប់នឹងស្នាមចង្អូរទឹក និងកន្លែងដែលពួកទាហានធ្លាប់ឈរយាម កាលពីជិត២ពាន់ឆ្នាំមុន គឺនៅសម័យ ដែលប្រជាជនបីម៉ឺននាក់ បានរស់នៅក្នុងទីក្រុងនេះ ដែលមានការរីកចម្រើន នៅក្នុងវាលរហោស្ថាន។

ពេលដែលយើងដើរកាត់តាមច្រកភ្នំនេះ ភ្លាមៗនោះ អ្នកនាំផ្លូវ ក៏បានប្រាប់យើងឲ្យឈប់ ហើយក៏បានឲ្យយើងបន្តកន្ទុយគ្នា ជាជួរ ហើយដាក់ដៃយើង នៅលើស្មារបស់អ្នកនៅមុខយើង រួចបិទភ្នែកយើង ហើយដើរអូសជើងទៅមុខ ទាល់តែដល់ពេលដែលគាត់ប្រាប់យើងឲ្យបើកភ្នែកវិញ។ ពេលដែលគាត់ប្រាប់យើងឲ្យបើកភ្នែក យើងក៏បានឃើញអគាររតនាគារដ៏ល្បីល្បាញ តាមប្រឡោះតូចមួយ នៅចុងច្រកភ្នំ។ អគារនេះត្រូវបានគេសាងសង់ ដោយដាប់ថ្មយ៉ាងជ្រៅ ចូលទៅក្នុងជញ្ជាំងថ្មពណ៌ក្រហម ដ៏ខ្ពស់ត្រដែត របស់ជ្រលងភ្នំនេះ។ វាជាទស្សនីយ៍ភាព ដែលយើងបានទន្ទឹងរង់ចាំទស្សនា។ វាជាលើកទីមួយហើយ ដែលយើងបានមើលឃើញទី

ក្រុងដ៏ចំណាស់នេះ ដែលមានពណ៌ក្រហមដូចផ្កាកូឡាប។

អ្នកប្រហែលជាធ្លាប់បានឃើញវា នៅក្នុងខ្សែភាពយន្ត ឬរូបភាពណាមួយ តែបើអ្នកបានមើលវាដោយផ្ទាល់ អ្នកនឹងចង់មើលវា មិនដាក់ភ្នែក។ ពេលដែលអ្នកបានដើរទស្សនាដល់កន្លែងចុងក្រោយហើយ អ្នកប្រាកដជាឆ្ងល់ថា តើមនុស្សនៅសម័យនោះ រស់នៅយ៉ាងដូចម្ដេចខ្លះ នៅក្នុងទីក្រុងនោះ ដែលមានទីតាំងក្នុងវាលរហោស្ថាននេបាត។ ទោះតំបន់ជុំវិញមានភាពសោះកក្រោះយ៉ាងណាក៏ដោយ សហគមន៍មួយនេះមានការរីកចម្រើន រហូតដល់ពេលដែលមានគ្រោះរញ្ជួយដីធំៗ ដែលបានកើតឡើងជាបន្តបន្ទាប់ នៅឆ្នាំ៦ នៃគ្រីស្ទសករាជ ដែលបណ្ដាលឲ្យគេបោះបង់ទីក្រុងនេះចោល។

អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ខ្ញុំមានឯកសិទ្ធិក្នុងការទស្សនាសំណង់បុរាណនេះ និងសំណង់បុរាណដទៃទៀត ដែលមានដូចជា ស្ដាតខូលូសៀម នៅទីក្រុងរ៉ូម ព្រះវិហារផាថេនុន នៅទីក្រុងអាថែម ទីក្រុងម៉ាសាដា នៅប្រទេសអ៊ីស្រាអែល និងទីក្រុងអេភេសូរ ដែលមានទីតាំងក្នុងប្រទេសទួរគីសព្វថ្ងៃ។ ទោះសំណង់ទាំងនោះមានការបែកបាក់យ៉ាងណាក៏ដោយ ក៏ពួកវាបានធ្វើជាភស្ដុតាង ដែលបានឆ្លុះបញ្ចាំង អំពីអ្វីដែលគេធ្លាប់មាន នៅទីកន្លែងទាំងនោះ កាលពីសម័យមុន។ ដូចនេះ អ្វីដែលនៅសេសសល់បានបង្កប់នូវភាពរុងរឿង គឺភាពរុងរឿងដែលមានការប្រេះបែកខូចខាត និងបាត់បង់ភាពដើម។

ភាពរុងរឿង ដែលប្រេះបែក ខូចខាត និងបាត់បង់ គឺជាអ្វីដែលយើងបានជួបប្រទះជារៀងរាល់ថ្ងៃ ក្នុងជីវិតរបស់យើង។ នៅក្នុងសៀវភៅនេះ យើងនឹងនិយាយ អំពីការប៉ងប្រាថ្នាផ្លូវភេទ ដែលមិនបរិសុទ្ធ និងខុសពីភាពដើម ដែលមនុស្សត្រូវជម្នះ។ តើការប៉ងប្រាថ្នាផ្លូវភេទនេះមានប្រភពមកពីណា?

បើសិនជាព្រះជាម្ចាស់បានបង្កើតមនុស្ស ឲ្យមានរូបភាពដូចព្រះអង្គ ដោយប្រទាននូវអពាហ៍ពិពាហ៍ តើការប៉ងប្រាថ្នាផ្លូវភេទ មានភាពខុសឆ្គង

ត្រង់ចំណុចណាខ្លះ? បើព្រះទ្រង់ប្រទានឲ្យយើងមានភេទ ដែលល្អ ស្រស់ស្អាត និងបរិសុទ្ធ ហេតុអ្វីបញ្ហាផ្លូវភេទបានក្លាយជាប្រភពនៃការខូចចិត្ត កំហុស ក្ដីអាម៉ាស និងបញ្ហារបស់មនុស្សជាច្រើន? ហេតុអ្វីបានជារឿងដែលល្អ ត្រូវគេធ្វើឲ្យបាត់បង់ភាពដើម តាមរបៀបជាច្រើន ហើយបានក្លាយជាប្រភពនៃទម្លាប់ ដែលបានចងរឹតយើងជាប់ទៅវិញ? ហេតុអ្វីបានជាជីវិតអពាហ៍ពិពាហ៍ និងទំនាក់ទំនងជាច្រើន បានជួបកាលលំបាក ជាញឹកញាប់ ជាជាងជួបក្ដីសុខ? ហេតុអ្វីបានជាយើងត្រូវតែតយុទ្ធនឹងការល្បួងម្ដងហើយម្ដងទៀត?

*ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ការរួមដំណេក គឺជាអំណោយមកពីព្រះ ជាព្រះពរ តែនៅក្នុងទំនាក់ទំនងប្ដីប្រពន្ធប៉ុណ្ណោះ ជាបរិបទដែលព្រះសព្វព្រះទ័យ និងសម្រាប់គោលបំណងជាក់លាក់មួយចំនួនដូចជាៈ ការបង្កើតកំណើត ការតភ្ជាប់ ការស្គាល់ និងការស្រឡាញ់គ្នា និងការផ្ដល់ក្ដីសុខឲ្យគ្នាទៅវិញទៅមក។*

បើយើងមិនបានសិក្សាអំពីបញ្ហានេះ ឲ្យបានត្រឹមត្រូវទេ នោះយើងមិនអាចស្វែងរកការព្យាបាលដ៏ត្រឹមត្រូវឡើយ។ បើសិនជាការខ្វះខាតការយល់ដឹង គឺជាឫសគុលនៃបញ្ហាផ្លូវភេទរបស់យើង នោះយើងគួរតែស្វែងរកចម្លើយ នៅក្នុងការស្រាវជ្រាវ ឬការអប់រំក្នុងព្រះគម្ពីរ។ បើបញ្ហាផ្លូវភេទរបស់យើង មានឫសគុលនៅក្នុង គំនៀបសង្គម ឬការគៀបសង្កត់ពីមតិភាគច្រើន នៅក្នុងសង្គម នោះយើងគួរតែស្វែងរកអ្នករំដោះ ដែលអាចជួយយើង ឲ្យកាត់ផ្ដាច់ច្រវ៉ាក់ដែលបានចងរឹតយើង។ ប៉ុន្តែ បើបញ្ហាផ្លូវភេទយើង ជាបញ្ហាខាងវិញ្ញាណ នោះយើងចាំបាច់ត្រូវប្រើដំណោះស្រាយដែលមកពីព្រះជាម្ចាស់។

ដូចនេះ ដើម្បីស្វែងរកចម្លើយ យើងចាំបាច់ត្រូវងាកទៅមើលដើមកំណើតរបស់មនុស្សជាតិ គឺងាកទៅមើលចំណុចចាប់ផ្ដើមនៃបញ្ហាគ្រប់

យ៉ាង ក្នុងពិភពលោក។ យើងត្រូវមានការយល់ដឹងឲ្យបានច្បាស់ អំពីសេចក្តីពិត ដែលមានចែងក្នុងព្រះគម្ពីរ ដែលបានបង្ហាញអំពីភាពស្មុគ្រស្មាញនៃបញ្ហាផ្លូវភេទរបស់មនុស្ស បន្ទាប់ពីមនុស្សដំបូងបានធ្លាក់ចូលក្នុងអំពើបាប។ សេចក្តីពិតនេះ នឹងជួយយើង មិនឲ្យមានការស្វែងយល់ខុស អំពីបញ្ហារបស់យើង ក៏ដូចជាជៀសវាងការសន្យា ឬដំណោះស្រាយដែលមានការបោកបញ្ឆោត។

សេចក្តីពិតនេះនឹងជួយយើងជម្នះការល្បួង ដែលនាំយើងឲ្យស្រមើរស្រមៃ និងឲ្យតម្លៃ ចំពោះការសប្បាយផ្លូវអារម្មណ៍ និងផ្លូវភេទ តាមជំនឿដ៏ល្ងីល្ងើ ដែលជឿថា ការសប្បាយទាំងនោះអាចធ្វើជាអ្នកជួយរំដោះយើង។ តុល្យភាពតាមព្រះគម្ពីរ ក៏នឹងជួយការពារយើង មិនឲ្យមានប្រតិកម្មឆ្លើយតប ដែលប្រឆាំងនឹងសាច់ឈាម និងធម្មជាតិ។ អំពើបាបរបស់មនុស្សដំបូង បានធ្វើឲ្យមានការយល់ខុស អំពីបំណងព្រះទ័យដែលព្រះមានសម្រាប់ផ្លូវភេទ ក៏ដូចជាយល់ខុស អំពីអ្វីៗផ្សេងទៀត។ ប៉ុន្តែ ផ្លូវភេទរបស់មនុស្សមានភាពប្រេះបែកយ៉ាងណាក៏ដោយ ក៏វានៅមានភាពល្អពិតប្រាកដ។

*ការធ្លាក់ចូលក្នុងអំពើបាបរបស់មនុស្សដំបូង គឺនៅពេលដែលអំពើបាបចូលក្នុងលោកិយ ដោយសារតែអ័ដាម និងនាងអេវ៉ា ដែលជាមនុស្សដំបូង មិនស្តាប់បង្គាប់ព្រះជាលើកដំបូង ដោយបរិភោគផ្លែដឹងខុសត្រូវ។*



*ទីពីរ*

## ចូរស្វែងយល់អំពីដើមកំណើតរបស់មនុស្ស

**ក្នុងព្រះគម្ពីរ មានព្រឹត្តិការណ៍តិចណាស់** ដែលនាំឲ្យមានផលវិបាក ដែលធ្ងន់ធ្ងរ ដូចព្រឹត្តិការណ៍ដែលបានកត់ទុក នៅក្នុងបទគម្ពីរលោកុប្បត្តិជំពូក៣។

ព្រឹត្តិការណ៍ទាំងនេះបាន និងបន្តមានផលប៉ះពាល់ មកលើជីវិតមនុស្សម្នាក់ៗ ហើយយើងមិនអាចយល់ព្រះគម្ពីរ ឬប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ឬក៏ជីវិតរបស់យើងផ្ទាល់បានឡើយ បើសិនជាយើងមិនបានយល់អំពីព្រឹត្តិការណ៍ នៅក្នុងបទគម្ពីរលោកុប្បត្តិជំពូក៣ទេនោះ។

ជំពូកនេះ បានចែងអំពីការល្បួងដែលអ័ដាម និងនាងអេវ៉ាដែលជាប្តីប្រពន្ធដំបូងបំផុត បានជួបប្រទះ ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិត។ ប៉ុន្តែ វាមិនគ្រាន់តែជារឿងរបស់ពួកគេប៉ុណ្ណោះទេ តែក៏ជារឿងរបស់យើងផងដែរ។ យើងមិនគ្រាន់តែបានជាប់នៅក្នុងផលវិបាកនៃការសម្រេចចិត្តរបស់ពួកគេប៉ុណ្ណោះទេ តែសាតាំងថែមទាំងបានប្រើយុទ្ធសាស្ត្រដដែលនេះ នៅក្នុងជំនាន់ទាំងអស់។ ដូចនេះ យើងអាចអានបទគម្ពីរលោកុប្បត្តិជំពូក៣ ដើម្បីឲ្យមានការយល់ដឹង អំពីល្បិចរបស់មេល្បួង និងលក្ខណៈនៃការល្បួង ដែលចូលមករកយើងជារៀងរាល់ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ

នេះមិនមែនជាគោលបំណងជាចម្បងរបស់យើង នៅក្នុងកូនសៀវភៅនេះទេ។ យើងនឹងសិក្សាបទគម្ពីរនេះ ដើម្បីស្វែងយល់អំពីផលវិបាក ដែលអំពើបាបមាន មកលើផ្លូវភេទរបស់យើង។



*យើងមិនអាចយល់ព្រះគម្ពីរ ឬប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ឬក៏ជីវិតរបស់យើងផ្ទាល់បានឡើយ បើសិនជាយើងមិនបានយល់អំពីព្រឹត្តិការណ៍ នៅក្នុងបទគម្ពីរលោកុប្បត្តិជំពូក៣ទេនោះ។*

បទគម្ពីរលោកុប្បត្តិ ជំពូក៣ មានភាពស៊ីជម្រៅ ក្នុងផ្នែកទេវសាស្ត្រ ដែលនិយាយអំពីអំពើបាបដែលចូលមកក្នុងលោកិយ សេចក្តីស្លាប់ដែលមនុស្សត្រូវជួប ព្រះបន្ទូលសន្យាដំបូងបំផុតរបស់ព្រះ និងផលវិបាកនៃអំពើបាប និងជីវិតរបស់មនុស្ស នៅក្នុងលោកិយដែលបានធ្លាក់ចូលក្នុងអំពើបាប។ ទោះជាយ៉ាងណាក៏ដោយ យើងចាំបាច់ត្រូវកត់សំគាល់ថា ព្រះគម្ពីរមិនបានចែង ឬផ្តល់តម្រុយទាល់តែសោះថា អំពើបាបទីមួយ ដែលមនុស្សដំបូងបានប្រព្រឹត្ត មានលក្ខណៈផ្លូវភេទ ឬជាអំពើអសីលធម៌ផ្លូវភេទនោះឡើយ។ ការរួមដំណេកមិនមែនជាអំពើបាបដំបូងបំផុត ដូចដែលអ្នកខ្លះបានលើកឡើង ដោយខុសឆ្គងនោះឡើយ។ តែអំពើបាបរបស់អ័ដាម និងនាងអេវ៉ា ពិតជាបានបណ្តាលឲ្យព្រះជាម្ចាស់មានការរៀបចំជាថ្មីសម្រាប់ទំនាក់ទំនងប្តីប្រពន្ធ ហើយផ្លូវភេទរបស់យើងក៏មានការខូចខាត និងមានស្លាកស្នាម។

នៅចុងបញ្ចប់ នៃរឿងនៃការបង្កើតរបស់ព្រះ យើងឃើញថា "អ័ដាមនឹងប្រពន្ធគាត់ក៏នៅជាអាក្រាតទទេ ឥតមានសេចក្តីអៀនខ្មាសឡើយ"(លោកុប្បត្តិ ២:២៥)។ នៅក្នុងបរិបទនៃទំនាក់ទំនងប្តីប្រពន្ធរបស់មនុស្សដំបូងបំផុត ព្រះគម្ពីរបានឲ្យតម្លៃ និងទទួលស្គាល់ថា ផ្លូវភេទរបស់មនុស្សជាសិរីល្អដែលព្រះប្រទានមកស្នាព្រះហស្តព្រះអង្គ។

ព្រោះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា "ទាំងអស់ជាការល្អប្រពៃ"(លោកុប្បត្តិ ១:៣១)។

*បទគម្ពីរ លោកុប្បត្តិ ជំពូក ១ និង ២ គឺជាទស្សនៈពីរយ៉ាង ដែលឆ្លុះបញ្ចាំងអំពីសកម្មភាពបង្កើតរបស់ព្រះជាម្ចាស់។ លោកុប្បត្តិ ជំពូក២ បានកត់ទុកយ៉ាងជាក់លាក់ អំពីការបង្កើតមនុស្សជាតិ និងស្របតាមលោកុប្បត្តិ ជំពូក១ ដែលកត់ទុកយ៉ាងជាក់លាក់ នូវទិដ្ឋភាពដែលធំជាង នៃការបង្កើតចក្រវាល និងផែនដី។*

ការពិពណ៌នាក្នុងកណ្ឌគម្ពីរលោកុប្បត្តិ អំពីប្តីប្រពន្ធមួយគូរនេះ ដែលព្រះទ្រង់បានបង្កើតឲ្យមានរូបភាពដូចទ្រង់ គឺត្រូវបានធ្វើឡើង ដែលមានការសប្បាយដ៏បរិសុទ្ធ នៅក្នុងការរួមរស់ ទាំងផ្លូវកាយ និងផ្លូវវិញ្ញាណ ក្នុងបរិបទនៃទំនាក់ទំនងប្តីប្រពន្ធដើមដំបូងដែលព្រះបានរៀបចំ។

ផ្លូវភេទរបស់ពួកគេដែលមិនមានការប្រឡាក់ប្រឡូក បានទាក់ទាញពួកគេឲ្យមានការជិតស្និទ្ធកាន់តែខ្លាំង ដោយពួកគេមានចិត្តរីករាយ ចំពោះគ្នាទៅវិញទៅមក។ ពួកគេបានឈរទល់មុខគ្នា នៅក្នុងសួនច្បារដែលព្រះបានរៀបចំឲ្យពួកគេ។ ដោយពួកគេមិនមានការខ្មាស់អៀន ឬការភ័យខ្លាចថា ដៃគូរបស់ខ្លួន នឹងរកឃើញចំណុចដែលមិនសក្តិសម ឬខ្វះខាតនោះឡើយ។ នាងអេវ៉ាបានឈរនៅ ពីមុខស្វាមីរបស់ខ្លួន ក្នុងភាពជាស្ត្រីដែលព្រះបានប្រទានមក ហើយអ័ដាមក៏បានឈរនៅចំពោះមុខនាង ដែលជាភរិយា ក្នុងភាពជាបុរស ដែលព្រះបានរៀបចំផងដែរ។ អ្នកទាំងពីរបានបោះជំហានទៅមុខជាមួយគ្នា ដោយភាពថ្លៃថ្នូ ភាពសុខដុម និងភាពបរិសុទ្ធផ្លូវកាយ ដោយការបំពេញឲ្យគ្នាទៅវិញទៅមក យ៉ាងអស្ចារ្យ។

គួរឲ្យស្តាយណាស់ ដែលរឿងរបស់ពួកគេមិនមានការបញ្ចប់ដ៏ល្អទេ ហើយបទគម្ពីរលោកុប្បត្តិ ជំពូក៣ បានប្រាប់យើង អំពីផ្លូវដ៏សោកសៅ ដែលពួកគេបានចាប់ផ្តើមធ្វើដំណើរ និងបន្សល់ទុកឲ្យមនុស្សជំនាក់ក្រោយ រហូតមកដល់ពេលសព្វថ្ងៃ។

*ឯពស់ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយទៅកាន់ស្ត្រីថា តើព្រះមានព្រះបន្ទូលហាមមិនឲ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ? ស្ត្រី*

ឆ្លើយតបថា យើងបរិភោគអស់ទាំងផ្លែឈើនៅក្នុងសួនច្បារបាន។ តែត្រង់ដើមឈើ១ដែលនៅកណ្តាលសួនច្បារនោះ ព្រះទ្រង់មានព្រះបន្ទូលថា កុំឲ្យបរិភោគផ្លែនោះឡើយ ថែមទាំងកុំឲ្យពាល់ប៉ះផង ក្រែងលោស្លាប់។ រួចពស់ក៏និយាយទៅស្ត្រីថា អ្នកមិនស្លាប់ជាពិតមែនទេ។ ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រមទាំងដឹងការខុសត្រូវផង។ កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្មមគួរនឹងចង់បាន ដើម្បីឲ្យបានប្រាជ្ញា នោះនាងក៏យកផ្លែមកបរិភោគ ព្រមទាំងចែកឲ្យដល់ប្ដីដែរ គាត់ក៏បរិភោគតាម។ នោះស្រាប់តែភ្នែករបស់អ្នកទាំង២បានភ្លឺឡើង ហើយគេដឹងថាខ្លួននៅជាអាក្រាត ក៏យកស្លឹកល្វាមកភ្ជាស់ធ្វើជាប្រដាប់ប៉ឹង។ រួចមកបានឮសំឡេងព្រះយេហូវ៉ាដ៏ជាព្រះ ដែលទ្រង់យាងក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ នោះអ័ដាម និងប្រពន្ធគាត់ ក៏ពួននឹងព្រះយេហូវ៉ាដ៏ជាព្រះនៅកណ្ដាលដើមឈើក្នុងសួនច្បារ។

ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ហៅរកអ័ដាមដោយព្រះបន្ទូលថា ឯងនៅឯណា? គាត់ទូលឆ្លើយថា ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួនច្បារ ក៏រត់ទៅពួន ដោយនឹកភ័យខ្លាច ពីព្រោះនៅខ្លួនទទេ នោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលសួរថា តើអ្នកណាប្រាប់ឲ្យឯងដឹងថា ឯងនៅខ្លួនទទេដូច្នេះ តើឯងបានស៊ីផ្លែឈើដែលអញហាមមិនឲ្យស៊ីឬអី អ័ដាមទូលទ្រង់ថា ស្ត្រីដែលទ្រង់បានប្រទានឲ្យនៅជាមួយនឹងទូលបង្គំ វាឲ្យផ្លែឈើនោះមកទូលបង្គំ ទូលបង្គំក៏ទទួលទានទៅ រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះបន្ទូលសួរទៅស្ត្រីថា ឯងបានធ្វើអ្វីដូច្នោះ នាងទូលឆ្លើយថា ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បានទទួលទាន។ រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះបន្ទូលទៅពស់ថា ដោយព្រោះឯងបានធ្វើដូច្នេះ នោះនៅក្នុងអស់ទាំងពួកសត្វស្រុក សត្វព្រៃ ឯងជាសត្វត្រូវបណ្ដាសាហើយ គឺឯងត្រូវលូនតែនឹងពោះ ហើយត្រូវស៊ីធូលីដីអស់១ជីវិត។ អញនឹងធ្វើឲ្យឯង ហើយ

និងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ។ ទ្រង់ក៏មានព្រះបន្ទូលទៅស្ត្រីវិញថា អញនឹងចំរើនឲ្យឯងមានសេចក្តីព្រួយលំបាកជាច្រើនឡើង ក្នុងវេលាដែលមានផ្ទៃពោះ ឯងនឹងបង្កើតកូនដោយឈឺចាប់ ចិត្តឯងនឹងប្រាថ្នាខាងឯប្តី ហើយប្តីនឹងត្រួតត្រាលើឯង។

រួចទ្រង់ក៏មានព្រះបន្ទូលទៅអ័ដាមថា ដោយព្រោះឯងបានស្តាប់តាមប្រពន្ធឯង ហើយស៊ីផ្លែឈើនោះ ដែលអញបានហាមមិនឲ្យស៊ីឡើយ នោះដីត្រូវបណ្តាសាដោយព្រោះឯង ឯងត្រូវរកស៊ីពីដីដោយនឿយហត់អស់១ជីវិត។ ដីនឹងដុះជាបន្លាហើយនឹងអញ្ចាញឲ្យឯង ឯងត្រូវស៊ីអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ។ ឯងនឹងបានអាហារស៊ីដោយការបែកញើស ដរាបដល់ឯងត្រឡប់ទៅជាដីវិញ ពីព្រោះអញបានយកឯងពីដីមក ដ្បិតឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ។ អ័ដាមបានឲ្យឈ្មោះប្រពន្ធគាត់ថា «អេវ៉ា» ពីព្រោះនាងជាម្តាយនៃមនុស្សទាំងអស់។ នោះព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ក៏ធ្វើអាវពីស្បែក ឲ្យអ័ដាម និងប្រពន្ធគាត់ពាក់បិទបាំងកាយ។

រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះបន្ទូលថា មើលមនុស្សបានត្រឡប់ដូចជាយើង១ដែរ ទាំងដឹងខុសត្រូវផង ឥឡូវខ្លាចក្រែងវាលូកដៃទៅបេះផ្លែជីវិតស៊ីទៀត ហើយរស់ជារៀងរាបដរាបទៅ។ ដូច្នេះ ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់ក៏បណ្តេញគាត់ពីសួនច្បារអេដែនចេញ ឲ្យទៅភ្ជួររាស់ដីដែលទ្រង់បានយកមកបង្កើតគាត់នោះវិញ។ ទ្រង់បណ្តេញមនុស្សចេញ ហើយដាក់ចេរូប៊ីននៅខាងកើតសួនច្បារអេដែន និងដាវ ដែលជាអណ្តាតភ្លើងរេបែរទៅគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត។



*ទី៣*

# អំពើបាបបានធ្វើឲ្យមនុស្សយកការសប្បាយផ្ទាល់ខ្លួនជាអទិភាព

**ព្រះ** **ជាម្ចាស់មានផែនការដ៏អស្ចារ្យ** សម្រាប់ផ្លូវភេទ និងទំនាក់ទំនងប្ដីប្រពន្ធរបស់មនុស្ស។ តែសាតាំងមានផែនការផ្ទុយពីនេះ។ យើងប្រហែលជាមានសំណួរជាច្រើន អំពីលក្ខណៈរបស់សត្វពស់ ដែលចេះនិយាយ ដែលបានល្បួងមនុស្សដំបូង។ ដើមកំណើតរបស់វា មានពេញទៅដោយអាថ៌កំបាំង។ ទោះជាយ៉ាងណាក៏ដោយ យើងអាចដឹងច្បាស់ថា សត្វពោះដែលបានល្បួងនាងអេវ៉ា គឺជាសាតាំង។ ហើយយើងក៏ចាំបាច់ត្រូវស្វែងយល់ខ្លះៗ អំពីយុទ្ធសាស្ត្ររបស់សាតាំង ព្រោះយើងក៏ជួបការល្បួងខាងផ្លូវភេទ នៅពេលដែលយើងត្រូវតយុទ្ធ ដើម្បីភាពបរិសុទ្ធខាងផ្លូវភេទ។

ពេលដែលវាល្បួងនាងអេវ៉ា ជាដំបូង វាបានបន្ថែមបន្ថយព្រះបន្ទូលព្រះ ។ ព្រះទ្រង់បង្គាប់ទៅអ័ដាមថា "ឯងនឹងស៊ីផ្លែទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត។ តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផល

ឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន"(លោកុប្បត្តិ ២:១៦-១៧)។ នៅក្នុងមាត់របស់សាតាំង មានទៅដោយការមួលកាច់ព្រះបន្ទូលដ៏សប្បុរស ឲ្យក្លាយជាការហាមឃាត់បែបអាត្មានិយម។ វាសួរនាងអេវ៉ាថា "តើព្រះមានព្រះបន្ទូលហាមមិនឲ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ?" នេះជាពាក្យចម្អក ដើម្បីវាយប្រហារមកលើសេចក្តីល្អ និងប្រាជ្ញារបស់ព្រះ ក៏ដូចជា ដើម្បីយកព្រះបន្ទូលព្រះ មកជជែកវែកញែក។ សំណួរនេះសមនឹងឲ្យនាងអេវ៉ាឆ្លើយបដិសេធដោយគ្មានអល់ឯក។ តែផ្ទុយទៅវិញ នាងបានសម្រេចចិត្តយកព្រះបន្ទូលព្រះអង្គមកប្រើដោយគ្មានការប្រុងប្រយ័ត្ន ដោយនិយាយបំភ្លើស អំពីបំរាមរបស់ព្រះអង្គ ("កុំប៉ះពាល់ផ្លែឈើនោះ") ហើយបន្ថយភាពធ្ងន់ធ្ងរនៃការព្រមានរបស់ទ្រង់ ឲ្យនៅទៀបបំផុត("ក្រែងលោស្លាប់")។

ក្នុងជំហានទីពីរ សាតាំងបាននិយាយបន្ទាបចរិកលក្ខណៈរបស់ព្រះ។ វាថា "អ្នកមិនស្លាប់ជាពិតមែនទេ។ ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រមទាំងដឹងការខុសត្រូវផង"។ វាបាននិយាយវាយប្រហារមកលើព្រះជាម្ចាស់ ដោយត្រង់ៗថា "ព្រះអង្គមិនពិតត្រង់ ហើយព្រះអង្គមានព្រះទ័យប្រណែន ឬខ្លាចគេល្អដូចព្រះអង្គ។ ការព្រមានរបស់ព្រះអង្គ គឺគ្មានន័យអ្វីទេ អ្នកនឹងមិនស្លាប់ឡើយ! ព្រះទ្រង់មិនល្អទេ ទ្រង់ប្រណែន ហើយតឹងរឹងពេក។ ទ្រង់មិនចាប់អារម្មណ៍ ចំពោះប្រយោជន៍ដ៏ល្អបំផុតរបស់អ្នក គឺគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។ ទ្រង់ជាជនផ្តាច់ការដែលពូកែប្រណែនដែលប្រើអំណាចព្រៃមកលើអ្នក ដើម្បីរក្សាអំណាច និងឯកសិទ្ធិផ្ទាល់ខ្លួនប៉ុណ្ណោះ។ ការគ្រប់គ្រងរបស់ទ្រង់ មានការគាបសង្កត់ ធ្វើឲ្យអ្នកមិនមានសេរីភាព"។

ការគិតដូចនេះ នៅតែបន្តមាន ក្នុងសម័យបច្ចុប្បន្ន ដោយមនុស្សបានយកក្រមសីលធម៌មកជជែកពិភាក្សា តាមការយល់ឃើញរៀងៗខ្លួន។

*បើគេមើលសើរៗ **ការចោតប្រកាន់របស់សាតាំង**ហាក់ដូចជាត្រឹមត្រូវ ព្រោះអ័ដាម និងនាងអេវ៉ាមិនបានស្លាប់ខាងរូបកាយភ្លាមៗទេ។ ប៉ុន្តែ ពាក្យសម្តីរបស់សាតាំងគឺជាការបោកបញ្ឆោតទាំងស្រុង។ នៅពេលដែលពួកគេធ្វើអំពើបាបភ្លាម អ្វីៗទាំងអស់ក៏បានផ្លាស់ប្តូរ។ ការប្រកបទាក់ទងដែលពួកគេមានជាមួយព្រះ ក៏បានបាក់បែក។ ទស្សនៈដែលពួកគេមានចំពោះខ្លួនឯង និងចំពោះគ្នាទៅវិញទៅមកក៏បានផ្លាស់ប្តូរ។ ការជំនុំជម្រះរបស់ព្រះបានធ្លាក់មកលើពួកគេ ហើយនៅពេលដែលថ្ងៃនៅរះនៅឡើយ ពួកគេក៏ត្រូវបានបណ្តេញចេញពីសួនច្បារ។ រស់ជាតិនៃការស្លាប់ខាងរូបកាយ ដែលពួកគេនឹងស្គាល់ ក្នុងពេលខាងមុខ គឺគ្រាន់តែជាចំណុចចម្បង នៃការផ្លាស់ប្តូររបស់ពួកគេ ចូលទៅក្នុងពិភពនៃសេចក្តីស្លាប់។*

ជំហានចុងក្រោយរបស់សាតាំង គឺតតាំងនឹងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។ ការដឹងខុសត្រូវ គឺមិនគ្រាន់តែជាចំណេះដឹងផ្នែកសីលធម៌ ឬក្រមសីលធម៌ប៉ុណ្ណោះឡើយ។



*ការដឹងខុសត្រូវ គឺមិនគ្រាន់តែជាចំណេះដឹងផ្នែកសីលធម៌ ឬក្រមសីលធម៌ប៉ុណ្ណោះឡើយ។*

បញ្ហានៅត្រង់ចំណុចនេះ គឺសាតាំងបានល្បួងនាងអេវ៉ា ឲ្យជឿថា នាងនឹងបានស្គាល់ការល្អ និងអាក្រក់ ដូចព្រះដែរ គឺវាចង់ប្រាប់នាងថា ការដឹងខុសត្រូវគឺជា "រឿងល្អ" ព្រោះនាងនឹងមានលក្ខណៈដូចព្រះ ដោយអាចកំណត់ថា អ្វីត្រូវ អ្វីខុស អ្វីល្អ អ្វីអាក្រក់។ ជាការពិតណាស់ នាងអេវ៉ាពិតជានឹងបានដឹងខុសត្រូវ តែតាមរបៀបខុសពីព្រះជាម្ចាស់។ នាងនឹងស្គាល់ការអាក្រក់ ព្រោះនាងនឹងបានជួបវាដោយផ្ទាល់ ហើយនាងនឹងស្គាល់ការល្អ ព្រោះនាងខ្វះវា។ ប៉ុន្តែ នាងមិនអាចកំណត់ការល្អ ឬការអាក្រក់បានទេ ព្រោះការអាក្រក់ឆ្លុះបញ្ចាំងអំពីចារិកលក្ខណៈរបស់សាតាំង ហើយការល្អឆ្លុះបញ្ចាំងអំពីចារិកលក្ខណៈរបស់ព្រះជាម្ចាស់។ បុរសនឹងស្ត្រីដំបូង បានរួមដៃគ្នាបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ហើយ

ទន្ទឹមនឹងនោះ ពួកគេក៏បានបំផ្លាញ និងធ្វើឲ្យខូចរូបភាពរបស់ព្រះ នៅក្នុងខ្លួនពួកគេ។ នាងអេវ៉ាបានប្រព្រឹត្ត ដោយផ្អែកទៅលើការសប្បាយផ្ទាល់ខ្លួន ដែលនាងបានយកជាអាទិភាព។ គឺដូចមានសេចក្ដីចែងថា "កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្មមគួរនឹងចង់បាន ដើម្បីឲ្យបានប្រាជ្ញា"។ សម្រាប់ខ្លួននាងផ្ទាល់ មូលដ្ឋាននៃការសម្រេចចិត្តរបស់នាង គឺមានភាពអាត្មានិយម ដូចនេះ នាងមិនបានទទួលស្គាល់អំណាចរបស់ព្រះបន្ទូលព្រះឡើយ គឺគ្រាន់តែបានចាត់ទុកព្រះបន្ទូលព្រះអង្គជាជម្រើសប៉ុណ្ណោះ។

*យើងចាំបាច់ត្រូវដឹងថា ព្រះគម្ពីរបានបង្រៀនថា **រូបភាពរបស់ព្រះនៅក្នុងមនុស្សបានខូច** តែមិនបានបាត់បង់នោះឡើយ។ ដូចនេះ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី សាវ័កយ៉ាកុបបានដាស់តឿនយើង មិនឲ្យដាក់បណ្ដាសារ "មនុស្ស ដែលកើតមកតាមរូបអង្គព្រះ"ឡើយ( យ៉ាកុប ៣:៩ )។*

ព្រះជាម្ចាស់គ្រាន់តែបានប្រាប់ពួកគេ មិនឲ្យបរិភោគផ្លែឈើនោះ និងប្រាប់អំពីលទ្ធផលដែលពួកគេនឹងទទួល បើសិនជាពួកគេបរិភោគវា។ តែព្រះអង្គមិនបានរៀបរាប់លើសពីនេះឡើយ។ បញ្ហាចម្បងនៅក្នុងបញ្ហាផ្លូវភេទដែលមានបាប គឺនៅពេលដែលយើងតាំងខ្លួនជាអ្នកកំណត់ថា អ្វីល្អសម្រាប់ខ្លួនយើង ដោយគិតថា "រូបកាយរបស់ខ្ញុំ គឺស្រេចតែខ្ញុំ"។

*អំពើបាបកើតមាន នៅពេលដែលយើងជឿលើខ្លួនឯង ខ្លាំងជាងជឿលើព្រះ។*

នាងអេវ៉ាក៏បានបរិភោគផ្លែឈើនោះ ដោយគិតថា វាមានប្រយោជន៍បំផុតសម្រាប់ខ្លួននាង។ ការបរិភោគផ្លែឈើនោះ ងាយស្រួលទេ តែវាបាននាំមកនូវផលវិបាកដ៏ធ្ងន់ធ្ងរបំផុត។ ព្រះគម្ពីរក៏បានចែងយ៉ាងខ្លី អំពីការឆ្លើយតបរបស់អ័ដាម យ៉ាងដូចនេះថា"នាងក៏យកផ្លែមកបរិភោគ ព្រមទាំង

ចែកឲ្យដល់ប្ដីដែរ គាត់ក៏បរិភោគតាម"។ តើអ័ដាម បានឈរនៅស្ងៀម ដោយមិនធ្វើអ្វីសោះ នៅពេល ដែលសត្វពស់កំពុងតែល្បួងនាងអេវ៉ាឬ? ព្រះគម្ពីរមិនបានចែងអំពីចំណុចនេះទេ។ តែយើងដឹងថា គាត់ពិតជាបានឮព្រះមានបន្ទូលបញ្ជាដោយផ្ទាល់ អំពីដើមឈើដឹងខុសត្រូវនោះ ហើយគាត់នឹងត្រូវទទួលខុសត្រូវ។



*អំពើបាបតែងតែធ្វើឲ្យយើងជឿថា វាមានប្រយោជន៍បំផុតសម្រាប់យើង ទោះវាទាស់ប្រឆាំងនឹងព្រះបន្ទូលព្រះយ៉ាងណាក៏ដោយ។*

អ័ដាម និងនាងអេវ៉ាក៏មានទោស ពីបទមិនស្ដាប់បង្គាប់ និងបះបោរប្រឆាំងនឹងព្រះ។ របៀបដែលអ្នកទាំងពីរធ្វើអំពើបាប គឺមិនខុសពីយើងរាល់គ្នាឡើយ។ យើងយកព្រះ និងព្រះបន្ទូលព្រះអង្គ ទៅដាក់នៅខាងក្រោយ ហើយយកការសប្បាយរបស់យើង ដាក់នៅខាងមុខ។ អំពើបាបតែងតែធ្វើឲ្យយើងជឿថា វាមានប្រយោជន៍បំផុតសម្រាប់យើង ទោះវាទាស់ប្រឆាំងនឹងព្រះបន្ទូលព្រះយ៉ាងណាក៏ដោយ។ អ័ដាម និងនាងអេវ៉ាបានកើតមានចិត្តស្រេកឃ្លានយ៉ាងខ្លាំង ដោយសារភាពទាក់ទាញរបស់ផ្លែឈើនោះ បានជាពួកគេមិនខ្វល់ថា ព្រះបានហាមពួកគេយ៉ាងដូចម្ដេចខ្លះ។

ក្នុងវប្បធម៌របស់មនុស្សនៅសម័យទំនើប មានមនុស្សជាច្រើនបានចាត់ទុកការហ៊ានប្រព្រឹត្តយ៉ាងនេះ ជាទង្វើរដ៏ក្លាហាន។ លោកគ្រូ ហារ៉ូល យូស្ទ័របានធ្វើការវាយតម្លៃមកលើទង្វើរបស់នាងអេវ៉ាថា :

> វាជាទង្វើរដ៏ក្លាហាន ... នាងបានឆ្លងព្រំដែននៃបំរាមរបស់ព្រះចូលទៅក្នុងការអ្វីដែលនាងមិនទាន់ស្គាល់។ នាងបាននាំភាពជាមនុស្សមកឲ្យយើងរាល់គ្នា ដោយមានទាំងការឈឺចាប់ និងការសប្បាយទាំងអស់ ... នេះជាព្រឹត្តិការណ៍នៃភាពក្លាហានបំផុត និងនាំមកនូវសេរីភាពបំផុត ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ... គេអាចថា នាងគឺជាវីរៈនារីនៅក្នុងរឿងនេះ ដោយនាងបាននាំទាំងស្វាមីរបស់នាង ឲ្យចូលទៅក្នុងពិភពនៃការទាមទា និងការសម្រេចចិត្តផ្នែកសីលធម៌។

ព្រះជាម្ចាស់មិនបានធ្វើការវាយតម្លៃយ៉ាងដូចនេះ ចំពោះទង្វើរបស់នាងអេវ៉ា និងចំពោះការឆ្លើយតបរបស់អ័ដាមនោះឡើយ។ វាមិនមែនជាទង្វើរដ៏ក្លាហាន ឬមានតម្លៃនោះឡើយ តែវាបាននាំមកនូវសេចក្ដីហិនវិនាសសម្រាប់ខ្លួនពួកគេ និងកូនចៅជំនាន់ក្រោយរបស់ពួកគេ។

មិនយូរប៉ុន្មានអ័ដាម និងនាងអេវ៉ាក៏បានដឹងថា ទង្វើរបស់ពួកគេបានធ្វើឲ្យខូចស្នាព្រះហស្ដព្រះអង្គ។ អ្វីៗទាំងអស់ក៏បានផ្លាស់ប្ដូរ មិនដូចមុនទៀត។ ការដែលពួកគេបានសម្រេចចិត្តបះបោរ ជាជាងស្ដាប់បង្គាប់ព្រះបានធ្វើឲ្យមានផលប៉ះពាល់ ឬបំពុលគ្រប់ផ្នែកទាំងអស់នៃលោកិយ បូករួមទាំងភាពជាមនុស្ស និងផ្លូវភេទរបស់យើងផងដែរ។



*ទី៤*

# ផ្លូវភេទ គឺជាជនរងគ្រោះទីមួយ នៃអំពើបាប

រស់ជាតិដំបូងនៃអំពើបាប គឺធ្វើឲ្យមនុស្សមានការពេញចិត្តណាស់ ព្រោះនាងអេវ៉ាមានចិត្តរីករាយនឹងផ្លែឈើដឹងខុសត្រូវ បានជានាងមានចិត្តចង់ចែករំលែកវា ជាមួយនឹងស្វាមីរបស់នាង។ ប៉ុន្តែ រស់ជាតិបន្ទាប់ គឺមានភាពល្វីងជូរចត់លើសពាក្យពណ៌នា។ អ័ដាម និងនាងអេវ៉ាក៏បានដឹងថា អំពើបាបមានផលប៉ះពាល់មកលើយើងផ្ទាល់ៗខ្លួន ដោយធ្វើឲ្យយើងបាត់បង់ភាពស្អាតស្អំ នៅខាងក្នុង ។ “នោះស្រាប់តែភ្នែករបស់អ្នកទាំង២បានភ្លឺឡើង ហើយគេដឹងថាខ្លួននៅជាអាក្រាត ក៏យកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់ប៉ឹង”។ ដូចនេះ គ្រាន់តែពួកគេបានបរិភោគផ្លែឈើនោះហើយភ្លាម ពួកគេក៏បានមើលឃើញខ្លួនឯង តាមរបៀបខុសពីមុខ។ ភាពអាក្រាតរបស់ពួកគេ មិនមែនជាអ្វីដែលទើបតែកើតមាននោះទេ ប៉ុន្តែ ភាពអាម៉ាស់ក៏បានគ្របដណ្តប់ពីលើភាពអាក្រាតរបស់ពួកគេ។ ចិត្តពួកគេមានការថប់បារម្ភ ចំពោះលក្ខណៈសម្បត្តិរបស់ពួកគេ គឺមិនគ្រាន់តែចំពោះអ្វីដែលពួកគេបានធ្វើប៉ុណ្ណោះឡើយ។

ផលផ្លែមួយ ក្នុងចំណោមផលផ្លែនៃអំពើបាបរបស់ពួកគេ គឺជាការដឹងថា ខ្លួនឯងមានភាពអាម៉ាស់ ដែលបានបណ្តាលពួកគេ ឲ្យប្រញាប់បិទបាំងកាយ។ អ័ដាម និងនាងអេវ៉ាបានបិទបាំងកេរ្តិ៍ខ្មាស់របស់ខ្លួន គឺជាភេទ

ដែលពួកគេមានខុសគ្នា។ លោកថម គ្លេតហ៊ីល(Tom Gledhill) បានចង្អុលបង្ហាញអំពីចំណុចសំខាន់នៃបញ្ហានេះ ដូចតទៅ :

> អំពើបាប នៃការបះបោរទាស់នឹងព្រះ បានធ្វើឲ្យពួកគេដឹងថា ខ្លួនឯងមានភាពអាម៉ាស់ នៅត្រង់កេរ្តិ៍ខ្មាស់របស់ខ្លួន។ ភាពអាក្រាតរបស់ពួកគេ ជាតំណាងឲ្យភាពងាយរងគ្រោះរបស់ពួកគេ នៅចំពោះព្រះនេត្រព្រះ។ ហេតុអ្វីបានជាតំបន់កេរ្តិ៍ខ្មាស់របស់ពួកគេ គឺជាចំណុចផ្តោតនៃភាពអាម៉ាស់របស់ពួកគេ? ហេតុអ្វីចំណុចផ្តោតនោះមិនមែនជាភ្នែករបស់ពួកគេ ដែលបានមើលផ្លែដឹងខុសត្រូវ ដោយចិត្តស្រេកឃ្លាន? ឬចិត្តរបស់ពួកគេ ដែលបានជ្រើសរើសយកការប្រឆាំងនឹងព្រះរាជបញ្ញារបស់ព្រះ? ឬដៃរបស់ពួកគេ ដែលបានប៉ះផ្លែដឹងខុសត្រូវ? កេរ្តិ៍ខ្មាស់របស់ពួកគេគឺជាចំណុចដែលធ្វើឲ្យអ្នកទាំងពីរមានភេទខុសគ្នា និងបានធ្វើឲ្យពួកគេមានការខ្មាស់អៀន នៅចំពោះមុខគ្នា និងនៅចំពោះព្រះ។ ពួកគេមានការភ័យខ្លាច ចំពោះការកេងចំណេញ ... ការបំពាន ឬការលួងលោម ដែលអាចកើតមាន នៅក្នុងកំរិតមួយ ដែលអ្នកទាំងពីរត្រូវតែស្វែងរកភាពសាច់តែមួយ។

ជាការពិតណាស់ ភាពអាក្រាតរបស់អ្នកទាំងពីរ មិនមែនជាបញ្ហាទេ។ តែកំហុស និងក្តីអាម៉ាស់របស់អ្នកទាំងពីរ គឺជាបញ្ហា ដែលមិនអាចបិទបាំង ដោយស្លឹកល្វាបាន។ ពួកគេក៏បានទទួលស្គាល់ចំណុចនេះផងដែរ។ ពេលដែលអ័ដាមបានបិទបាំងកាយដោយស្លឹកល្វាហើយ គាត់ក៏បានពន្យល់ អំពីមូលហេតុដែលគាត់ពួននៅក្នុងគុម្ពោធព្រៃថា "ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួនច្បារ ក៏រត់ទៅពួន ដោយនឹកភ័យខ្លាច ពីព្រោះនៅខ្លួនទទេ"។ បើសិនជាគាត់បានដណ្តប់កាយទាំងមូល ដោយស្លឹកល្វា នោះគាត់ក៏នៅតែមានអារម្មណ៍ថា គាត់មានភាពអាក្រាត នៅចំពោះមុខព្រះដ៏បរិសុទ្ធ។

ជាការពិតណាស់ នៅពេលនោះផ្លូវភេទរបស់មនុស្ស បានទទួលផលប៉ះពាល់ភ្លាមៗពីអំពើបាប។ អ័ដាមមានការចាប់ចិត្ត ចំពោះស្ត្រីដែលព្រះបានបង្កើតឲ្យគាត់ ហើយភាពអាក្រាតដែលពួកគេបានពិសោធន៍នៅក្នុង

សួនច្បារ គឺមិនមានការខ្មាស់អៀន ដោយវាជាស្នាព្រះហស្តដ៏ល្អរបស់ព្រះ។ ប៉ុន្តែ ការបះបោររបស់ពួកគេ បាននាំឲ្យផ្លូវភេទរបស់ពួកគេទទួលផលប៉ះពាល់ដោយផ្ទាល់ ពីអំពើបាប ដោយពួកគេមានការព្រួយបារម្ភអំពីកេរ្តិ៍ខ្មាស់របស់ខ្លួន។ កេរ្តិ៍ខ្មាស់របស់ពួកគេ បានក្លាយជា "ផ្នែកឯកជន" របស់ពួកគេ។

សូមយើងគិត អំពីភាពពុករលួយដែលបានកើតពីការខូចខាតនៃផ្លូវភេទដែលខុសពីធាតុដើម ដែលមានដូចជាកំហុស ក្តីអាម៉ាស់ ការឈឺចាប់ ការបំពាន ការញៀន អំពើហឹង្សា ។ល។ អំណោយដ៏ល្អរបស់ព្រះជាម្ចាស់ ក៏បានខូចខាតខុសពីធាតុដើម។ អំពើបាបបានធ្វើឲ្យអ្វីៗដែលល្អ ប្រែជាបាត់បង់លក្ខណៈដើម ហើយកែប្រែឲ្យក្លាយជាអាវុធសម្រាប់បង្ខូចបំផ្លាញ។ ក្នុងសៀវភៅ ដែលលោកនាល ផ្លានទីងហ្កា(Neal Plantinga) បាននិពន្ធ មានចំណងជើងថា វាមិនគួរប្រែជាបែបនេះ គាត់មិនបាននិយាយអំពីបញ្ហាផ្លូវភេទដោយលម្អិតទេ ប៉ុន្តែ គាត់បានបញ្ជាក់យ៉ាងច្បាស់ថា "អំពើបាបបានបំផ្លាញមុខងារដ៏មានអំណាចរបស់មនុស្ស ដែលមានដូចជា គំនិត អារម្មណ៍ ការនិយាយ និងសកម្មភាព ដោយធ្វើឲ្យមុខងារទាំងនោះចេះវាយប្រហារ ឬមានការខូចខាត ឬក៏មិនត្រូវបានអើពើ"។



*អំពើបាបបានធ្វើឲ្យអ្វីៗ ដែលល្អ ប្រែជាបាត់បង់ លក្ខណៈដើម ហើយកែប្រែឲ្យក្លាយជាអាវុធ សម្រាប់បង្ខូចបំផ្លាញ។*

កាលពីដំបូងព្រះជាម្ចាស់បានបង្កើតប្តីប្រពន្ធទាំងពីរឲ្យមានចិត្តប្រាថ្នារកគ្នា តែបន្ទាប់ពីពួកគេបានធ្វើអំពើបាប ពួកគេក៏បានលាក់ខ្លួនពីគ្នា។ ពួកគេក៏បានចាប់ផ្តើមមានតម្រេករកគ្នាទៅវិញទៅមក។ អ្វីដែលពួកគេធ្លាប់តែធ្វើ ដោយមិនត្រូវអៀនខ្មាស់ ក៏បានក្លាយជាប្រភពនៃការអៀនខ្មាស់ និងការត្រេកត្រអាល ដែលមានក្តីអាម៉ាស់។ ក្នុងសៀវភៅដែលលោកដេននីសហូលីង្គ័រ(Dennis Hollinger) បាននិពន្ធមានចំណងជើងថា "អត្ថន័យនៃ

ផ្លូវភេទ ″ គាត់បានមានប្រសាសន៍ថា ផ្លូវភេទរបស់មនុស្ស នៅតែជាផ្លូវភេទ និងអំណោយរបស់ព្រះសម្រាប់មនុស្សជាតិ ទោះវាបានខូចដោយសារអំពើបាបហើយក៏ដោយ។ វាបានបាត់បង់ភាពដើមដ៏បរិសុទ្ធ នៅក្នុងការត្រេកត្រអាល ទិសដៅ គោលបំណង ការដើរផ្លូវខុស និងការជំរុញឲ្យមានកំហុស″។

ដើមកំណើតនៃក្ដីអាម៉ាស់ មានការជាប់ទាក់ទងនឹងដើមកំណើតនៃការមិនទុកចិត្ត។ អំពើបាបមានផលប៉ះពាល់មកលើយើង ដោយធ្វើឲ្យយើងបាត់បង់ភាពស្និទ្ធស្នាល និងការទុកចិត្តគ្នា។ ស្លឹកល្វាដែលអ្នកទាំងពីរបានយកមកបាំងកាយ គឺជាភស្ដុតាងបញ្ជាក់អំពីគំលាត និងការដាច់ចេញពីគ្នា ដែលអ្នកទាំងពីរបានជួប។ ការបិទបាំងកាយខ្លួនឯង គឺជារោគសញ្ញានៃភាពអាម៉ាស់ ដោយពួកគេមិនបើកចំហរចំពោះគ្នា ដូចមុនទៀតឡើយ។ គេយល់ថា ពួកគេមិនអាចមើលមុខគ្នាចំដូចមុន ព្រោះពួកគេមានអារម្មណ៍ថា ពួកគេងាយនឹងរងគ្រោះ នៅចំពោះមុខគ្នា។

អំពើបាបធ្វើឲ្យយើងមានការលាក់បាំង ចំពោះគ្នា។ វាក៏នាំឲ្យយើងបង្កការឈឺចាប់មកលើគ្នាទៅវិញទៅមកផងដែរ។ ពេលដែលពួកគេប្រឈមមុខដាក់ព្រះជាម្ចាស់ បន្ទាប់ពីបានធ្វើខុស អ័ដាមក៏បានបន្ទោសព្រះ និងនាងអេវ៉ា ដោយមិនព្រមទទួលខុសត្រូវ ចំពោះទង្វើរបស់ខ្លួន។ គាត់ថា ‴ស្ដ្រីដែលទ្រង់បានប្រទានឲ្យនៅជាមួយនឹងទូលបង្គំ វាឲ្យផ្លែឈើនោះមកទូលបង្គំ ទូលបង្គំក៏ទទួលទានទៅ″។ ដោយសារការបដិសេធន៍ និងការដោះសារនេះ ផ្លូវភេទដែលព្រះប្រទាន សម្រាប់ធ្វើជាព្រះពរ ក៏បានប្រែក្លាយជាជម្លោះ។ ការតាំងខ្លួនឯងជាមនុស្សសុចរិត ច្រើនតែរាប់បញ្ចូលការបោកប្រាស់ខ្លួនឯង គឺដូចនៅក្នុងរឿងនេះជាដើម។ អំពើបាប គឺដូចជាមេរោគអញ្ចឹង។ វាបានធ្វើឲ្យខូចទំនាក់ទំនងដ៏មានតម្លៃបំផុតរបស់មនុស្ស។

ព្រះគម្ពីរបានចែងថា ‴រួចមកបានឮសំឡេងព្រះយេហូវ៉ាដ៏ជាព្រះ ដែលទ្រង់យាងក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ″។ ត្រង់ចំណុចនេះ យើងមិនដឹង

ថា ត្រូវកាត់ស្រាយឲ្យបានដាក់លាក់យ៉ាងដូចម្តេចទេ។ យើងមិនដឹងច្បាស់ អំពីលក្ខណៈនៃបទពិសោធន៍ដែលពួកគេមាននៅពេលនោះទេ តែបទគម្ពីរ នេះបានបង្ហាញយ៉ាងច្បាស់ថា វាជាផ្នែកមួយនៃទំនាក់ទំនងដែលព្រះជាម្ចាស់មានជាប្រចាំ ជាមួយមនុស្សដំបូង ដែលជាស្នាព្រះហស្តព្រះអង្គ នៅសម័យនោះ។ ប៉ុន្តែ ពេលនោះ ពួកគេមានការភ័យខ្លាច ពេលដែលពួកគេឮសម្លេងព្រះអង្គយាងមក គឺមិនមានអារម្មណ៍រីករាយដូចមុនទេ។ ពួកគេក៏បានឆ្លើយតបចំពោះស្ថានភាពនៅពេលនោះ ដោយការគេចមុខពីព្រះអង្គ តាមសុភាវគតិរបស់ខ្លួន គឺមិនបានចូលទៅជិតព្រះអង្គទៀតទេ។ គឺដូចមានសេចក្តីចែងថា "អ័ដាម និងប្រពន្ធគាត់ ក៏ពួននឹងព្រះយេហូវ៉ាដ៏ជាព្រះ នៅកណ្តាលដើមឈើក្នុងសួនច្បារ"។

វាជាលើកទីមួយ ដែលពួកគេមានការភ័យខ្លាច និងដឹងថាខ្លួនឯងមានកំហុស នៅចំពោះព្រះវត្តមានព្រះ គឺមិនមានអារម្មណ៍ចង់ជួបព្រះអង្គ និងអរសប្បាយនោះឡើយ។ ការប្រកបទាក់ទងដែលពួកគេមានជាមួយព្រះ ក៏បានបាក់បែក។ អំពើបាបមានផលប៉ះពាល់ខាងវិញ្ញាណ មកលើយើងរាល់គ្នា ធ្វើឲ្យយើងបាត់បង់ការប្រកបទាក់ទង និងបណ្តាលឲ្យមានការបាត់បង់ជីវិតខាងវិញ្ញាណ។ ជាដំបូង អ័ដាម និងនាងអេវ៉ាមានការភ័យខ្លាចចំពោះព្រះ ហើយបន្ទាប់មកក៏បានគេចមុខពីព្រះអង្គ ហើយទីបំផុតពួកគេក៏បានប្រកែកជាមួយព្រះអង្គ ពេលដែលព្រះអង្គប្រឈមមុខដោះស្រាយបញ្ហាដែលពួកគេបានបង្ករឡើង។ ពួកគេបានព្យាយាមទម្លាក់កំហុសមកលើគ្នាទៅវិញទៅមក និងមកលើសត្វពស់ ហើយថែមទាំងបានទម្លាក់កំហុសមកលើព្រះជាម្ចាស់ទៀតផង។ ព្រះជាម្ចាស់ក៏បានឆ្លើយតប ដោយមានបន្ទូលដ៏មុឺងម៉ាត់ អំពីផលវិបាកជាអចិន្ត្រៃរបស់អំពើបាបរបស់ពួកគេ ដែលរាប់បញ្ចូលទាំងការបណ្តេញពួកគេចេញពីសួនច្បារជារៀងរហូត(លោកុប្បត្តិ ៣:១៦-២៤)។

តើមានរឿងអ្វីកើតឡើង? បុរសនិងស្ត្រីដំបូងនោះ បានសម្រេចចិត្ត

បំពានព្រះរាជបញ្ញា ដែលព្រះជាម្ចាស់បានបង្គាប់យ៉ាងច្បាស់ សម្រាប់ជាព្រះពរ និងការការពារពួកគេ។ ការសម្រេចចិត្តប្រឆាំង និងមិនស្តាប់បង្គាប់តាមព្រះបន្ទូលដែលបានចេញពីព្រះឱសរបស់ព្រះ គឺជាការប្រឆាំង និងមិនស្តាប់បង្គាប់ព្រះអង្គដោយផ្ទាល់។ គឺដូចដែលលោកធីម៉ូថេ វ៉ែត (Timothy Ward) បានសង្កេតឃើញថា "ពេលដែលមនុស្សដកព្រះរាជបញ្ញារបស់ព្រះជាម្ចាស់ចេញ ដើម្បីបំពេញបំណងប្រាថ្នា តាមប្រាថ្នារបស់ខ្លួន គឺមានន័យថា ពួកគេបានដកព្រះអង្គចេញពីការសម្រេចចិត្តរបស់ពួកគេហើយ"។

សណ្តាប់ធ្នាប់នៃស្នាព្រះហស្តរបស់ព្រះ បានប្រែក្លាយជាគ្មានសណ្តាប់ធ្នាប់។ ការប្រាថ្នាចង់បានការរួមរស់ជាសាច់តែមួយ ក៏លែងមានរបៀបរៀបរយ ដោយការធុញថប់ ការប៉ះទង្គិចគ្នា និងការស្វែងរកការសប្បាយជាមួយគ្នា ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ។ គឺដូចដែលមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់ នៅក្នុងរឿងជាច្រើនទៀត ដែលបានចែងក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ដែលមានដូចតទៅ : ផលផ្លែដំបូងនៃស្នេហារបស់អ័ដាម និងនាងអេវ៉ា បានបង្កើតឲ្យមានកាអ៊ីន។ កាអ៊ីនក៏បានសម្លាប់អេបិល ដែលជាប្អូនប្រុសរបស់ខ្លួន ដោយសារការច្រណែន(លោកុប្បត្តិ ៤)។ នៅសម័យក្រោយមកទៀត នាងសារ៉ា និងនាងរ៉ាដែលបានជួបការលំបាក ដោយសារពួកគេជាស្ត្រីអារ។ ទំនាកទំនងប្តីប្រពន្ធដែលក្លាយជាសាច់តែមួយ តាមបំណងព្រះទ័យព្រះ ក៏ត្រូវបានគេបង្ខូចឲ្យទៅជាទំនាក់ទំនងដែលមានប្តីឬប្រពន្ធច្រើន ហើយវាបាននាំឲ្យមានផលវិបាកជាច្រើន ដែលមានដូចជាជម្លោះដ៏សោកសៅ ដែលនាំឲ្យមានការបែកបាក់ នៅក្នុងក្រុមគ្រួសាររបស់លោកអ័ប្រាហាំ អ៊ីសាក់ និងយ៉ាកុប។ ជាងនេះទៅទៀត ការធ្លាក់ចុះសីលធម៌ធ្ងន់ធ្ងរទូទាំងពិភពលោក បាននាំឲ្យមានទឹកជំនន់ពេញផែនដី(លោកុប្បត្តិ ៦) ហើយក្រោយមក ក៏មានអំពើហឹង្សាដែលជាការប៉ុនប៉ងរំលោភផ្លូវភេទ អសីលធម៌ផ្លូវភេទនៃក្រុងសូដុម និងកូម៉ូរ៉ា(លោកុប្បត្តិ ១៩) ការរំលោភផ្លូវភេទមកលើនាងឌីណា(លោកុប្បត្តិ ៣៤) និងការធ្លាក់ចុះនៃ

សីលធម៌ផ្លូវភេទ នៅក្នុងរឿងរបស់នាងតាម៉ា ដែលត្រូវគេធ្វើបាប ក្នុងបទគម្ពីរលោកុប្បត្តិ ជំពូក៣៨ ដែលស្ថិតក្នុងចំណោមរឿងអាស្រូវបំផុត នៅក្នុងព្រះគម្ពីរប៊ីប។

ពិភពលោកថ្មីរបស់យើង នៅក្រៅសួនច្បារអេដែន បានឃ្លាតចាកចេញឆ្ងាយ ពី "ភាពល្អប្រសើរ" នៅក្នុងបទគម្ពីរលោកុប្បត្តិ ជំពូក១។ ហើយគ្មាននរណាម្នាក់ដែលអាចជៀសរួចពីភាពខូចខាត ដែលបណ្តាលមកពីការធ្លាក់ចូលក្នុងអំពើបាប របស់មនុស្សដំបូងនោះឡើយ។



*ទី៥*

## គ្មានផ្លូវត្រឡប់បែរក្រោយ ... មានតែផ្លូវទៅមុខ

រឿងដែលបានកើតឡើងនៅក្នុងសួនច្បារអេដែន គឺជារឿងដែលសោកសៅបំផុត តែព្រះជាម្ចាស់ក៏បានប្រទាននូវដំណោះស្រាយផងដែរ។ ព្រះអង្គមិនបានបោះបង់អ័ដាម និងនាងអេវ៉ា ឬកំចាត់ពួកគេចោលនោះឡើយ ទោះពួកគេបានធ្វើអំពើបាប និងមានកំហុសយ៉ាងណាក៏ដោយ។ ពេលដែលព្រះអង្គមានបន្ទូលថា "ឯងនៅឯណា?" គឺព្រះអង្គកំពុងតែបង្ហាញឲ្យគេដឹងថា ព្រះអង្គជាព្រះដែលស្វែងរកមនុស្សបាត់បង់។ ទ្រង់បានសួរពួកគេ មិនមែនដោយសារព្រះអង្គមិនដឹងថា ពួកគេនៅទីណានោះទេ។ ព្រះអង្គជាព្រះសព្វញ្ញូញាណ។ ព្រះអង្គកំពុងស្វែងរកពួកគេ និងចង់ឲ្យពួកគេប្រែចិត្ត ដោយស្មោះអស់ពីចិត្ត។ ព្រះអង្គជ្រាបច្បាស់ថា ពួកគេកំពុងលាក់ខ្លួន នៅក្នុងគម្ពោធព្រៃ ទាំងជណ្តប់កាយដោយស្លឹកល្វា ហើយព្រះអង្គជ្រាបថា ហេតុអ្វីពួកគេនៅកន្លែងនោះ។ ដោយសារព្រះអង្គស្រឡាញ់ និងយកព្រះទ័យទុកដាក់ចំពោះពួកគេ នោះព្រះអង្គមិនបានអើពើរចំពោះការដោះសារដ៏ឥតប្រយោជន៍របស់ពួកគេនោះឡើយ ហើយក៏បានជំរុញពួកគេឲ្យនិយាយការពិត។

ទន្ទឹមនឹងនោះ ដោយសារព្រះគុណរបស់ព្រះអង្គ នោះព្រះអង្គក៏បានប្រកាស់ការជំនុំជម្រះមកលើសត្វពស់ ដោយឲ្យសាតាំងបរាជ័យ នៅក្រោមដៃរបស់កូនចៅជំនាន់ក្រោយរបស់នាងអេវ៉ា ដែលមានចំណែកនៅក្នុងការធ្លាក់ចូលក្នុងអំពើបាប។ ផែនការប្រោសលោះដែលព្រះអង្គបានរៀបចំ

ដើម្បីរំដោះមនុស្សឲ្យរួចពីបាប គឺបានសម្រេចនៅសម័យក្រោយមកទៀត តាមរយៈព្រះអម្ចាស់យេស៊ូវ ដោយព្រះអង្គនឹងវាយបំបាក់សាតាំង តាមរយៈជ័យជម្នះរបស់ព្រះអង្គ នៅលើឈើឆ្កាង។ ព្រះយេស៊ូវគឺជាព្រះដែលយាងមកយកកំណើតជាមនុស្សតាមព្រះបន្ទូលសន្យា ដើម្បីបញ្ចប់កិច្ចការរបស់សាតាំង(លោកុប្បត្តិ ៣:១៤-១៥)។

ជាការពិតណាស់ អ័ដាមពិតជាមានការសោកសៅយ៉ាងខ្លាំង ពេលដែលបានឮការប្រកាស់ អំពីការជំនុំជម្រះរបស់ព្រះ និងដឹងអំពីផលវិបាកនៃអំពើបាប។ គ្មានផ្នែកណាមួយនៃជីវិតគាត់ ដែលមិនមានការផ្លាស់ប្តូរនោះទេ។ អ្វីៗមិនដូចពីមុនទៀតឡើយ។ អ័ដាមនឹងត្រូវធ្វើការដាំដុះនៅលើដី យ៉ាងលំបាកពេញមួយជីវិត ហើយគាត់ក៏បានស្លាប់នៅចុងបញ្ចប់នៃជីវិតគាត់ ព្រោះគាត់ "ជាធូលីដី គឺត្រូវត្រឡប់ជាធូលីដីវិញ"។ នៅក្នុងព្រះបន្ទូលរបស់ព្រះ អំពីការជំនុំជម្រះ អ័ដាមក៏បានឮព្រះបន្ទូលសន្យារបស់ព្រះ អំពីជ័យជម្នះលើអំពើបាប និងការអាក្រក់នៅទីបញ្ចប់។ អ័ដាមបានហៅឈ្មោះប្រពន្ធគាត់ថា "អេវ៉ា" ព្រោះនាងជាម្តាយនៃមនុស្សទាំងអស់។ នៅក្នុងព្រះគម្ពីរដើមជាភាសាហេព្រើរ ពាក្យ "អេវ៉ា" គឺជាទម្រង់មួយទៀតនៃពាក្យជាភាសាហេព្រើ ដែលមានន័យថា "ជីវិត"។ នេះជាឈ្មោះដ៏ចម្លែកដែលអ័ដាមបានជ្រើសរើស! សរុបមក អំពើបាបរបស់ពួកគេបាននាំមកនូវសេចក្តីស្លាប់។ គេជឿថា អ័ដាមបានសម្រេចចិត្តជ្រើសរើសឈ្មោះនេះ ឲ្យនាងអេវ៉ា គឺដោយសារគាត់បានជឿព្រះបន្ទូលសន្យារបស់ព្រះ ដែលផ្ទុយនឹងការមិនទុកចិត្ត និងការមិនស្តាប់បង្គាប់ ដែលស្ថិតនៅក្នុងចំណុចកណ្តាលនៃការបះបោររបស់គាត់។

បន្ទាប់មក ព្រះជាម្ចាស់ក៏បានប្រទានមូលដ្ឋានគ្រឹះនៃសេចក្តីសង្ឃឹម ដោយព្រះអង្គ "ធ្វើអាវពីស្បែក ឲ្យអ័ដាម និងប្រពន្ធគាត់ពាក់បិទបាំងកាយ"។ បើយើងគិតមិនបានស៊ីជម្រៅទេ យើងប្រហែលជាយល់ថា ព្រះអង្គហាក់ដូចជាគ្រាន់តែបង្ហាញសេចក្តីសប្បុរសជាធម្មតា ចំពោះពួកគេ

ដោយព្រះអង្គជំនួសខោអាវធ្វើពីស្លឹកឈើ ដោយខោអាវស្បែកសត្វដែលអាចប្រើបានយូរជាង។ ប៉ុន្តែ បើយើងគិតឲ្យជ្រៅជាងនេះ យើងនឹងធ្វើការសន្និដ្ឋានដែលមានន័យជាងនេះ។ ខោអាវធ្វើពីស្លឹកល្វា គឺជាតំណាងឲ្យសុភាវគតិរបស់អ្នកទាំងពីរ និងដំណោះស្រាយមិនគ្រប់ជ្រុងជ្រោយសម្រាប់បិទបាំងកំហុស និងក្តីអាម៉ាស់របស់ពួកគេ។ ពួកគេអាចបិទបាំងកេរ្តិ៍ខ្មាស់របស់ពួកគេ តែពួកគេមិនអាចដកក្តីអាម៉ាស់ចេញបានឡើយ។ ពួកគេនៅតែមានអារម្មណ៍ថា ខ្លួននៅអាក្រាតនៅចំពោះព្រះដ៏បរិសុទ្ធ។ ប៉ុន្តែ ពេលនេះ ព្រះជាម្ចាស់បានប្រទានខោអាវសម្រាប់បិទបាំងកាយពួកគេដោយផ្ទាល់ ដោយទ្រង់ប្រហែលជាត្រូវសម្លាប់សត្វណាមួយ(ដែលទំនងជាប្រភពនៃ "ខោអាវស្បែក")។ បើដូច្នោះមែន គេជឿថា ការស្លាប់ដំបូងបំផុតបន្ទាប់ពីការធ្លាក់ចូលក្នុងអំពើបាប គឺជាការស្លាប់របស់សត្វមួយក្បាល ដើម្បីផ្តល់ឲ្យនូវស្បែកសម្រាប់បិទបាំងកាយពួកគេ។ ការបិទបាំងកាយនេះ ជាអំណោយមកពីព្រះ ដែលព្រះអង្គបានប្រទានទាំងស្រុង ហើយពួកគេមិនបានរកដោយខ្លួនឯងទេ។ រឿងនេះក៏បានចង្អុលបង្ហាញយើងឲ្យងាកទៅរកព្រះអម្ចាស់ យេស៊ូវ ដែលបានប្រទានការលះបង់ដ៏ឥតខ្ចោះ ដើម្បីឲ្យយើងអាចហ៊ុមព័ទខ្លួនដោយសេចក្តីសុចរិតរបស់ទ្រង់។

គឺដូចដែលបទគម្ពីរ ២កូរិនថូស ៥:២១ បានចែងថា "ឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង"។

ទោះព្រះជាម្ចាស់បានប្រទានពន្លឺនៃក្តីសង្ឃឹមហើយក្តី ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យអ័ដាម និងនាងអេវ៉ា បន្តរស់នៅក្នុងសួនច្បារអេដែនទៀតឡើយ។ ពួកគេបានបោះបង់ចោលសិទ្ធិ សម្រាប់ការរស់នៅដូចកាលពីដើមដំបូងហើយ។

អំពើបាបរបស់ពួកគេបានធ្វើឲ្យប្រឡាក់អ្វីៗគ្រប់យ៉ាង។ ដូចនេះ ព្រះជាម្ចាស់ក៏បាន "បណ្តេញមនុស្សចេញ ហើយដាក់ចេរូប៊ីននៅខាងកើតសួន

ច្បារអេដែន និងដាវ ដែលជាអណ្ដាតភ្លើងរេបេរទៅគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត″។

សេចក្ដីសុខដែលពួកគេធ្លាប់មានក្នុងសួនច្បារ មិនគ្រាន់តែបានបាត់បង់ប៉ុណ្ណោះទេ តែពួកគេថែមទាំងមិនអាចស្វែងរកក្ដីសុខនោះមកវិញតាមសមត្ថភាពរបស់មនុស្សបានឡើយ។ ការអះអាងថា មនុស្សអាចបង្កើតឲ្យមានសេចក្ដីសុខនោះឡើងវិញ គឺជាការផ្ដល់ឲ្យនូវក្ដីសង្ឃឹមក្លែងក្លាយ។ ប៉ុន្តែ ចុងបញ្ចប់នៃសួនច្បារអេដែនមិនមែនជាចុងបញ្ចប់នៃរឿងរបស់ព្រះ ឬរឿងរបស់យើងឡើយ។ ព្រះជាម្ចាស់ប្រទានផ្លូវមួយ សម្រាប់ឲ្យអ័ដាម និងនាងអេវ៉ាបន្តដំណើរទៅមុខទៀត ក្នុងការធ្វើដំណើរមួយដែលនឹងឈានដល់ចំណុចដែលមានន័យបំផុតនៅពេលព្រះគ្រីស្ទសុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ព្រមទាំងបញ្ចប់ទៅវិញ ដោយការយាងមកវិញរបស់ព្រះអង្គ ដើម្បីបង្កើតផ្ទៃមេឃ និងផែនដីថ្មី។



ការដែលព្រះអម្ចាស់យេស៊ូវ ដែលជាព្រះរាជបុត្រានៃព្រះ បានយកកំណើតជាមនុស្ស គឺទ្រង់បានបញ្ជាក់ច្បាស់បំផុត អំពីបំណងព្រះទ័យរបស់ព្រះអង្គ សម្រាប់រូបកាយយើង។

ការដែលព្រះអម្ចាស់យេស៊ូវ ដែលជាព្រះរាជបុត្រានៃព្រះ បានយកកំណើតជាមនុស្ស គឺទ្រង់បានបញ្ជាក់ច្បាស់បំផុត អំពីបំណងព្រះទ័យរបស់ព្រះអង្គ សម្រាប់រូបកាយយើង។ ព្រះគ្រីស្ទមិនបានចាប់កំណើងជាមនុស្សអភេទនោះទេ។ តែព្រះអង្គបានចាប់កំណើតជាមនុស្សប្រុស ដែលជាអត្តសញ្ញាណនៃភេទ ដែលបញ្ជាក់ថា ព្រះអង្គជានរណា។ ពេលដែលព្រះអង្គសុគតនៅលើឈើឆ្កាង ក្នុងនាមជាកូនចៀមនៃព្រះ ដោយទទួលយកអំពើបាបរបស់យើង គឺព្រះអង្គមិនគ្រាន់តែបានដាន់ក្បាលសត្វពស់ប៉ុណ្ណោះទេ តែថែមទាំងបានផ្សះផ្សាទំនាក់ទំនងរវាងមនុស្សនឹងព្រះឡើងវិញផងដែរ។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ មិនគ្រាន់តែជាភស្តុតាងបញ្ជាក់

អំពីជ័យជម្នះដែលព្រះអង្គមានមកលើសេចក្តីស្លាប់ តែក៏បានបញ្ជាក់អំពីគោលបំណងរបស់ព្រះអង្គ នៅក្នុងការកែទម្រង់រូបភាពរបស់ព្រះអង្គ នៅក្នុងយើង។ ភាពបរិសុទ្ធដែលព្រះអង្គសព្វព្រះទ័យឲ្យយើងមាន គឺមិនគ្រាន់តែជាការជៀសចេញពីអំពើបាបខាងផ្លូវភេទប៉ុណ្ណោះទេ តែក៏ជាការផ្លាស់ប្រែឲ្យមានចរិយាសម្បត្តិកាន់តែដូចព្រះអង្គ។ ហើយយើងក៏ទន្ទឹងរង់ចាំពេល ដែលព្រះអង្គនឹងយាងមកវិញ ក្នុងសិរីល្អ ហើយយើងនឹងទទួលរូបកាយថ្មីដែលបានរស់ពីស្លាប់ឡើងវិញ នៅពេលដែលព្រះអង្គសម្រេចផែនការប្រោសឲ្យរស់ឡើងវិញ និងប្រោសលោះ នូវអ្វីៗទាំងអស់ នៅក្នុងព្រះគ្រីស្ទ។

នៅក្នុងសៀវភៅដែលលោកយ៉ូស្វេ ហារីស(Joshua Harris) បាននិពន្ធមានចំណងជើងថា ផ្លូវភេទមិនមែនជាបញ្ហាទេ គាត់បានសរសេរថា "សេចក្តីពិតនោះគឺថា ព្រះយេស៊ូវមិនបានយាងមក ដើម្បីរំដោះយើងឲ្យរួចផុតពីភាពជាមនុស្សឡើយ តែព្រះអង្គបានយកកំណើតជាមនុស្ស ដើម្បីរំដោះយើង ឲ្យរួចពីបាប។ ព្រះអង្គមិនបានយាងមកសង្គ្រោះយើង ឲ្យរួចពីជីវិតដែលមានភេទនោះទេ តែព្រះអង្គបានយាងមក ដើម្បីសង្គ្រោះយើងឲ្យរួចពីចំណងនៃអំពើបាប និងការត្រេកត្រអាលផ្លូវភេទ ដែលបំផ្លាញផ្លូវភេទរបស់យើង"។

យើងមានបទពិសោធន៍ដ៏ឈឺចាប់ក្នុងជីវិត ពេលដែលយើងដឹងថា យើងមិនអាចវិលត្រឡប់ថយក្រោយបាន។ ពេលដែលព្រហ្មចារី ឬភាពបរិសុទ្ធបានបាត់បង់ហើយ គឺយើងមិនអាចរកវាមកវិញបានឡើយ។ យើងមិនអាចវិលត្រឡប់មករកភាពដើមបាន ពេលដែលអំពើកំផិតត្រូវបានប្រព្រឹត្តិហើយ ឬពេលដែលគំនិតរបស់យើងបានខូចដោយសារមើលរូបអាសអាភាស ឬការពិសោធន៍ផ្លូវភេទ ។ល។ ប៉ុន្តែ ព្រះរាជសារដ៏រុងរឿងនៃដំណឹងល្អបានប្រាប់យើងថា យើងត្រូវធ្វើដំណើរឆ្ពោះទៅមុខ តាមរយៈដំណឹងល្អរបស់ព្រះគ្រីស្ទ។ យើងត្រូវតែជៀសវាងការបិទបាំងខ្លួនដោយ

ស្លិកល្វា ដើម្បីលាក់បាំងកំហុស និងក្ដីអាម៉ាស់របស់យើង ដូចអ័ដាម និងនាងអេវ៉ានោះឡើយ។ យើងចាំបាច់ត្រូវឈរ ក្នុងជាតុពិតរបស់យើង នៅចំពោះព្រះដ៏បរិសុទ្ធ ដោយទុកចិត្តព្រះបន្ទូលសន្យារបស់ទ្រង់ ដែលនឹងគ្របបាំងយើង ដោយសេចក្ដីសុចរិតនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលបានប្រទានមក តាមរយៈការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាង។ យើងមិនអាចឲ្យពេលវេលាត្រឡប់ថយក្រោយបានឡើយ តែដោយសារជំនឿនោះ យើងអាចបោះជំហានទៅមុខ ក្រោមការផ្គត់ផ្គង់របស់ព្រះអម្ចាស់យេស៊ូវ និងរួមដំណើរជាមួយ ដោយព្រះវិញ្ញាណរបស់ព្រះអង្គ។

យើងជាសំណល់បាក់បែក ដែលព្រះជាម្ចាស់ធ្វើឲ្យរុងរឿងឡើងវិញ។ យើងបានបាត់បង់ជាតុដើមដែលព្រះអង្គបានបង្កើត។ គឺភាពប្រេះបែក និងពុករលួយ ដែលមានពេញប្រវត្តិសាស្ត្រ គឺជាភស្តុតាងបញ្ជាក់អំពីបញ្ហានេះ។ តែរូបភាពរបស់ព្រះ នៅតែស្ថិតស្ថេរ។ ភាពខ្វះចន្លោះនៃផ្លូវភេទរបស់យើង ជាភស្តុតាងបង្ហាញអំពីការធ្លាក់ចូលអំពើបាបរបស់មនុស្សដំបូង តែវាក៏ជាភស្តុតាងបញ្ជាក់ អំពីការបង្កើតរបស់ព្រះជាម្ចាស់ កាលពីដើមដំបូង។

ហើយយើងបន្តដំណើរទៅមុខ ក្នុងអំណាចរបស់ព្រះគ្រីស្ទ ដែលជួយសង្គ្រោះ និងក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដែលញែកជាបរិសុទ្ធ ដោយទុកចិត្តថា ព្រះអង្គកំពុងតែធ្វើការក្នុងយើង ហើយយើង "កំពុងតែកែឡើងខាងឯសេចក្ដីចេះដឹង ឲ្យបានត្រូវនឹងរូបអង្គព្រះ ដែលបង្កើតមនុស្សថ្មីនោះមក"(កូល៉ុស ៣:១០)។

យើងមិនគ្រាន់តែថ្វាយសិរីល្អដល់ព្រះ ដោយជៀសវាងអំពើបាបខាងផ្លូវភេទប៉ុណ្ណោះទេ ដោយនេះជាអ្វីដែលព្រះបន្ទូលព្រះបានត្រាស់ហៅយើងឲ្យធ្វើ។ ប៉ុន្តែ យើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ បានពេញលេញបំផុត ពេលដែលយើងស្គាល់គោលបំណង ដែលព្រះអង្គបានបង្កើតយើង ហើយប្រើអំណោយទានដ៏ល្អរបស់ព្រះអង្គ ដោយអំណរ តាមបំណងព្រះទ័យព្រះអង្គ។

រឿងនៃការបង្កើតរបស់ព្រះ បានបកស្រាយយ៉ាងច្បាស់ អំពីចំណុចសំខាន់បីយ៉ាង គឺ :

- ផ្លូវភេទគឺជាព្រះពរដែលព្រះប្រទាន។ គឺជាគំនិតរបស់ព្រះ មិនមែនជាគំនិតយើងទេ។
- ផ្លូវភេទគឺជាអ្វីដែលព្រះអង្គសព្វព្រះទ័យឲ្យមនុស្សមាន តែក្នុងបរិបទនៃទំនាក់ទំនងប្តីប្រពន្ធប៉ុណ្ណោះ។
- ផ្លូវភេទ ត្រូវបានព្រះទ្រង់រៀបចំមក ក្នុងគោលបំណង ដើម្បីឲ្យមនុស្សមានភាពស្និទ្ធស្នាល។

ពេលណាយើងទុកចិត្តព្រះអង្គ ដោយរស់នៅ ក្នុងព្រំដែនដែលព្រះអង្គបានកំណត់ ក្នុងចំណុចទាំងបីខាងលើនេះ នៅក្រោមអំណាចរបស់ព្រះអង្គ នោះមានន័យថា យើងកំពុងតែថ្វាយសិរីល្អដល់ព្រះអង្គ ហើយយើងកំពុងតែបង្ហាញចេញ និងអរសប្បាយនឹងជីវិតដែលគាប់ព្រះហឫទ័យព្រះអង្គ។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូប មានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្តីពិតនៃព្រះយេស៊ូវគ្រីស្ទ ដល់លោកិយ ដោយប្រើធនធានដែលមានតុល្យភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុត ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឈោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានគ្រីស្ទបរិស័ទជាច្រើនបានរួមចំណែកក្នុងការដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្តី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឈោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលប្រាក់ជំនួយពីក្រុម ឬនិកាយណាមួយឡើយ។